**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ០១៩ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១២

# សេចក្តីណែនាំ
## ស្តីពី
## ការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

យោងព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

យោងសេចក្តីសម្រេចលេខ ០០៣/១១ ល.ស អ.ប.ព ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ របស់អង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីទម្រង់បែបបទ និងនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល។

យោងប្រកាសលេខ ១០៤ ប្រ.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ក្រសួងមហាផ្ទៃ។

យោងលិខិតលេខ ០៨១/១២ ល.ស អ.ប.ព ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១២ របស់អង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីសេចក្តីបំភ្លឺពីការប្រកាសទ្រព្យសម្បត្តិ និងបំណុលសម្រាប់អ្នកលាលែងដោយកាតព្វកិច្ចច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រក្សាឃុំ សង្កាត់ និងការកំណត់ជាទូទៅមួយចំនួនសម្រាប់ប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី២។

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំអំពីការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដូចខាងក្រោម ៖

### ១. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាប់ឆ្នោតឡើងវិញសម្រាប់អាណត្តិថ្មី

ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណា ដែលធ្លាប់បានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិមុន ហើយបានជាប់ឆ្នោតឡើងវិញជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិថ្មី ត្រូវអនុវត្តការប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរបបប្រកាស០២ឆ្នាំម្តង។

ប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរបបប្រកាស០២ឆ្នាំម្តង ត្រូវដំណើរការតាមកាលបរិច្ឆេទដូចខាងក្រោម ៖

| ប្រសិនបើប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកដំបូងនៅក្នុងថ្ងៃណាមួយ (គិតថ្ងៃយកឯកសារប្រកាសមកដល់ អ.ប.ព) ក្នុងឆ្នាំ | ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី២ នៅថ្ងៃទី | ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី៣ នៅថ្ងៃទី | ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី៤ នៅថ្ងៃទី |
|---|---|---|---|
| ឆ្នាំ២០១១ | ១-៣១ មករា ២០១៣ | ១-៣១ មករា ២០១៥ | ១-៣១ មករា ២០១៧ |
| ឆ្នាំ២០១២ | ១-៣១ មករា ២០១៤ | ១-៣១ មករា ២០១៦ | ១-៣១ មករា ២០១៨ |



ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

| | | | |
|---|---|---|---|
| ឆ្នាំ២០១៣ | ១-៣១ មករា ២០១៥ | ១-៣១ មករា ២០១៧ | ១-៣១ មករា ២០១៩ |
| ឆ្នាំ២០១៤ | ១-៣១ មករា ២០១៦ | ១-៣១ មករា ២០១៨ | ១-៣១ មករា ២០២០ |
| ឆ្នាំ២០១៥ | ១-៣១ មករា ២០១៧ | ១-៣១ មករា ២០១៩ | ១-៣១ មករា ២០២១ |

**សម្គាល់** ៖ ទ្រព្យសម្បត្តិ និងបំណុលដែលមានក្រោយថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១ (ថ្ងៃកំណត់ចុងក្រោយនៃការប្រកាសទ្រព្យសម្បត្តិដំបូង) ត្រូវប្រាប់ពីប្រភពនៃទ្រព្យសម្បត្តិនោះ។

## ២. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនជាប់ឆ្នោតឡើងវិញសម្រាប់អាណត្តិថ្មី

ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណា ដែលបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិមុន ប៉ុន្តែមិនបានជាប់ឆ្នោតឡើងវិញជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិថ្មីទេ ហើយមិនមាននៅសល់មុខតំណែងផ្សេងទៀតដែលត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលទេនោះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលក្នុងរង្វង់៣០ថ្ងៃ គិតចាប់ពីថ្ងៃបើកកិច្ចប្រជុំដំបូងដើម្បីប្រកាសសុពលភាពក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។

ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ "ខ" បានបើកកិច្ចប្រជុំដំបូងដើម្បីប្រកាសសុពលភាពក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២។ លោក "ឃ" ជាសមាជិកក្រុមប្រឹក្សាឃុំ "ខ" ក្នុងអាណត្តិមុន តែមិនបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំក្នុងអាណត្តិថ្មីនេះទេ។ ដូច្នេះ លោក "ឃ" ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលយ៉ាងយូរបំផុតត្រឹមថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២ បន្ទាប់ពីការចាកចេញពីតំណែងសមាជិកក្រុមប្រឹក្សាឃុំ "ខ"។

## ៣. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់ឆ្នោតលើកដំបូង

ចំពោះបុគ្គលណាដែលទើបបានឈរឈ្មោះបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ហើយបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់លើកដំបូង ទោះជានៅក្នុងអាណត្តិណានៃក្រុមប្រឹក្សាឃុំ សង្កាត់ក៏ដោយ ហើយមិនធ្លាប់បានប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរយៈមុខតំណែងផ្សេងទេ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី១របស់ខ្លួនក្នុងរង្វង់៣០ថ្ងៃ បន្ទាប់ពីថ្ងៃបើកកិច្ចប្រជុំដំបូងដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ "ខ" បានបើកកិច្ចប្រជុំដំបូងដើម្បីប្រកាសសុពលភាពក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២។ លោក "ង" ទើបតែបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំជាលើកដំបូង សម្រាប់អាណត្តិថ្មីនៃក្រុមប្រឹក្សាឃុំ "ខ"។ រយៈពេលកន្លងមក លោក "ង" មិនធ្លាប់បានប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរយៈមុខតំណែងផ្សេងឡើយ។ ដូច្នេះ លោក "ង" ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី១របស់ខ្លួន យ៉ាងយូរបំផុតត្រឹមថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២។

## ៤. អំពីការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

បន្ទាប់ពីការចូលកាន់តំណែង ជាធម្មតាតែងតែមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួន ត្រូវបានផ្លាស់ប្តូរដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ដូច្នេះ ក្នុងករណីឃុំ សង្កាត់ណាមានការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ ឬសង្កាត់នោះត្រូវណែនាំឲ្យធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលផ្លាស់ប្តូរ ដូចខាងក្រោម ៖

**ក. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្តូរចេញ**

ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាដែលត្រូវបានប្តូរចេញ ហើយមិនមានសល់មុខតំណែងផ្សេងដែលត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ សមាជិករូបនោះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលក្នុងរង្វង់៣០ថ្ងៃ មុនការចាកចេញពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

ឧទាហរណ៍ លោក “ក” ជាសមាជិកក្រុមប្រឹក្សាឃុំ “ខ” ត្រូវបានស្នើសុំប្តូរចេញដោយមូលហេតុបាត់បង់សមាជិកភាពពីគណបក្សនយោបាយ “គ”។ ក្រសួងមហាផ្ទៃបានចេញប្រកាសស្តីពីការប្តូរឈ្មោះ “ក” ចេញពីសមាជិកក្រុមប្រក្សាឃុំ “ខ” នាថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២។ ដូច្នេះ ឈ្មោះ “ក” ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ បន្ទាប់ពីការចាកចេញពីតំណែងសមាជិកក្រុមប្រឹក្សាឃុំ “ខ”។

**ខ. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្តូរចូល**

ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាដែលត្រូវបានប្តូរចូល ហើយមិនធ្លាប់បានប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរយៈមុខតំណែងផ្សេងទេ សមាជិករូបនោះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ក្នុងរង្វង់៣០ថ្ងៃ បន្ទាប់ចូលកាន់មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

ឧទាហរណ៍ លោក “ឃ” ត្រូវបានស្នើសុំប្តូរចូលជាសមាជិកក្រុមប្រឹក្សាឃុំ “ខ” ជំនួសឈ្មោះ “ក” ខាងលើនេះ។ ក្រសួងមហាផ្ទៃបានចេញប្រកាសស្តីពីការប្តូរឈ្មោះ “ឃ” ចូលជាសមាជិកក្រុមប្រឹក្សាឃុំ “ខ” នាថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២។ ដូច្នេះ ឈ្មោះ “ឃ” ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ បន្ទាប់ពីការចូលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាឃុំ “ខ”។

## ៥. ការណែនាំបន្ថែម

ក្រុមជំនួយការរបស់ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិល នៅថ្នាក់រាជធានី ខេត្ត ត្រូវសហការជាមួយអភិបាលក្រុង ស្រុក ខណ្ឌ ជួយណែនាំ និងដាស់តឿនក្រើនរំលឹកដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅក្នុងរាជធានី ខេត្តរបស់ខ្លួន ឲ្យផុសផុលចូលរួមអនុវត្តការប្រកាសទ្រព្យសម្បត្តិ និងបំណុល។ ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលនេះ សាមីខ្លួនអាចផ្ញើមកអង្គភាពប្រឆាំងអំពើពុករលួយតាមរយៈក្រុមជនបង្គោលប្រឆាំងអំពើពុករលួយក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិល ឬប្រកាសនៅអង្គភាពប្រឆាំងអំពើពុករលួយដោយផ្ទាល់។

ការខកខានមិនបានប្រកាសទ្រព្យសម្បត្តិ និងបំណុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០១(មួយ)ខែ ទៅ០១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០.០០០(មួយសែន)រៀល ទៅ២.០០០.០០០(ពីរលាន)រៀល ហើយត្រូវបានបង្ខំឲ្យធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុលជូនអង្គភាពប្រឆាំងអំពើពុករលួយ ដូចមានចែង ក្នុងមាត្រា៣៨ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

ទទួលបានសេចក្តីណែនាំខាងលើនេះ អភិបាលរាជធានី ខេត្ត ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិល និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

រដ្ឋមន្ត្រីស្តីទី

ឧបនាយករដ្ឋមន្ត្រី ស ខេង

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់
- ឯកសារ-កាលប្បវត្តិ